ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៨ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់របៀបរបបការងារ និង ការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

****+****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** កំណត់របៀបរបបការងារ និង បែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី និង ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និង ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដូចមានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២ :** នាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងាររួមរបស់គណរដ្ឋមន្ត្រី និង ចាត់ចែងបញ្ហារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

ប្រការ ៣ : ឧបនាយករដ្ឋមន្ត្រី÷

១- ឯកឧត្តម **ស ខេង**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជានាយករដ្ឋមន្ត្រីស្ដីទី ពេលនាយក-រដ្ឋមន្ត្រីអវត្តមាន, ជួយនាយករដ្ឋមន្ត្រីលើការងារសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ការជួញដូរមនុស្ស, ដឹកនាំប្រតិបត្តិការទប់ស្កាត់ និង ប្រឆាំងភេរវកម្ម, ដឹកនាំគណកម្មាធិការជាតិកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (គជវវ) និង ការ-បំផ្លាញចោលអាវុធ ព្រមទាំងការងារភូមិ-ឃុំមានសុវត្ថិភាព ។

២- ឯកឧត្តម **សុខ អាន**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការសម្រាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និង បណ្តាឧបនាយករដ្ឋមន្ត្រី, ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដាន សម្របសម្រួលដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម, ដឹកនាំផ្ទាល់អាជ្ញាធរប្រេងកាតជាតិកម្ពុជា អាជ្ញាធរអប្សរា គណៈកម្មាការយូណេស្កូ និង ក្រុមប្រឹក្សាអ្នកច្បាប់ ព្រមទាំងជួយនាយករដ្ឋមន្ត្រីក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា ស្របតាមនីតិវិធីដូចមានចែងក្នុង មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ ។

៣- ឯកឧត្តម **ទៀ បាញ់**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការងារការពារជាតិ, ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ដឹកនាំកិច្ចការបញ្ជូនកង-កម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និង ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការបញ្ជាអង្គភាពពិសេសប្រឆាំងភេរវកម្ម ក្នុងពេលនាយករដ្ឋមន្ត្រីអវត្តមាន ។

៤- ឯកឧត្តម **គាត ឈន់**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃជំនួសនាយករដ្ឋមន្ត្រី, ទទួលបន្ទុកការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការងារអភិវឌ្ឍន៍វិស័យឯកជន, ការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍជាមួយគូអង្គអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ, ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និង សម្រេចលើការងាររបស់ **«ច្រកចេញ-ចូលតែមួយ»** នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលែងតែការងារដែលមានវេទយិតភាពខ្ពស់ ដែលតម្រូវឱ្យសុំការ-ណែនាំ ឬ ការសម្រេចពីនាយករដ្ឋមន្ត្រី និង ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យ និង សម្រេចលើសំណើរសុំកូន និង ការសុំលាសញ្ជាតិ ។

៥- ឯកឧត្តម **ហោ ណាំហុង**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស និង សហ-ប្រតិបត្តិការអន្តរជាតិទូទៅ ។

៦- លោកជំទាវ **ម៉ែន សំអន**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារអធិការកិច្ច និង សវនកម្ម ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារសង្គម ។

៧- ឯកឧត្តម **ប៊ិន ឈិន**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ព្រមទាំងជួយនាយករដ្ឋមន្ត្រីលើការងារបង្ការ, ទប់ស្កាត់ និង ប្រឆាំងអំពើពុករលួយ ។

៨- ឯកឧត្តម **យឹម ឆៃលី**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

៩- ឯកឧត្តម **កែ គឹមយ៉ាន**: ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំផ្ទាល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ប្រការ ៤ :** នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ ៥ :** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកអនុវត្តការងារ ឬ បេសកកម្មផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ :** ឧបនាយករដ្ឋមន្ត្រី ១ រូបៗ មានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ, ២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ, និង ជំនួយការ ៥ រូប ក្នុងនោះ ១ រូប មានឋានៈស្មើអគ្គនាយក, ២ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ៧ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស÷

១- ឯកឧត្តម **ញឹម វណ្ណដា**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

២- ឯកឧត្តម **ឃុន ហាំង**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានប្រចាំការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៣- ឯកឧត្តម **លី ធុជ**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ២ នៃគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង ទទួលបន្ទុក ESCAP ។

៤- ឯកឧត្តម **ចំន្ទ សារុន**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

៥- ឯកឧត្តម **ឱម យ៉ិនទៀង**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំគណកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល និង អង្គភាពប្រឆាំងអំពើពុករលួយ ។

៦- ឯកឧត្តម **អៀង ម៉ូលី**: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ។

៧- ឯកឧត្តម ទ៉ា គីមហុង: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន ។

៨- ឯកឧត្តម យឹម ឆៃលី: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកការងារក្រុមសង្កេតការណ៍សេដ្ឋកិច្ច, សង្គមកិច្ច និង វប្បធម៌ ។

៩- ឯកឧត្តម សៅ កុសល: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកអនុប្រធានប្រចាំការគណកម្មាធិការជាតិ ជំរុញចលនាភូមិមួយ- ផលិតផលមួយ ។

១០- ឯកឧត្តម ហ៊ឹម ឆែម: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីអំពីការងារវប្បធម៌ ។

១១- ឯកឧត្តម ខិន ម៉ុនសារ៉ន: ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ។

**ប្រការ ៨ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៩ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ១ រូបៗ មានជំនួយការ ៥ រូប ក្នុងនោះ ២ រូប មានឋានៈស្មើ អគ្គនាយក, ១ រូប មានឋានៈស្មើ អគ្គនាយករង និង ២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ១០ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១ :** នាយករដ្ឋមន្ត្រី, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

***កន្លែងទទួល:***

*- ក្រសួងព្រះបរមរាជវាំង*

*- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- ទីស្តីការគណៈរដ្ឋមន្ត្រី*

*- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*

*- ដូចប្រការ ៣, ៧ និង ១១*

*- ឯកសារ- កាលប្បវត្តិ*